

# គោលការណ៍ណែនាំត្រឡប់ចូលសាលារៀន 2023-24

សាលារៀនភាគច្រើនចាប់ផ្តើមបើកនៅថ្ងៃទី30 ខែសីហា ។

**CAMS និង Sato ចាប់ផ្តើមបើកនៅថ្ងៃទី16 ខែសីហា ។**

សូមទាក់ទងសាលារៀនប្រចាំតំបន់របស់លោកអ្នកសំរាប់ព័ត៌មានបន្ថែម ។

LONG BEACH
UNIFIED SCHOOL DISTRICT
*Excellence & Equity*

# ជំនួយគាំទ្រពីលោកអ្នកអាចបង្កើតឧត្តមភាពបាន

ជូនចំពោះមាតាបិតា និងអាណាព្យាបាលជាទីគោរព

សូមអរគុណចំពោះលោកអ្នកដោយបានជ្រើសរើសយកមណ្ឌលអប់រំ ឡុងប៊ីច ដែលជាកន្លែងឆ្នាំសិក្សាថ្មីនាំមកនូវឱកាសជាច្រើនសំរាប់លទ្ធផលជោគជ័យដល់សិស្ស ។ សាលារៀនរបស់យើងជាប់ឈ្មោះល្បីដោយសារតែមានការឆ្នៃប្រឌិត កម្មវិធីសិក្សាជាកំរិតម៉ឹងម៉ាត់ កម្មវិធីសិល្បៈជាកំរិតខ្ពស់ និងកម្មវិធីកីឡាជាកំរិតដ៏អស្ចារ្យ ។ សំខាន់ជាងនេះទៅទៀត យើងត្រូវបានជាប់ឈ្មោះទទួលស្គាល់ដោយសារតែមានការប្តេជ្ញាចិត្តយ៉ាងជ្រៅជ្រះទៅកាន់ឧត្តមភាព និងសមធម៌សំរាប់សិស្សទាំងអស់ ។

ខ្ញុំសូមលើកទឹកចិត្តទៅកាន់លោកអ្នកអោយធ្វើការចាត់ទុកអំពីគោលការណ៍ណែនាំត្រឡប់ចូលសាលារៀនវិញនេះជាសៀវភៅដៃមួយសំរាប់ "សេចក្តីដកស្រង់មុនគេ" ដែលមានផ្តល់ជាព័ត៌មានសង្ខេបដ៏សំខាន់ៗ និងបញ្ជីត្រួតពិនិត្យសំរាប់ជួយសំរួលដល់ការចាប់ផ្តើមឆ្នាំសិក្សាអោយបានងាយស្រួល ។ ដូចពេលដរាបមក គឺព័ត៌មាន យ៉ាងលំអិត និងសេចក្តីប្រកាសផ្សេងៗចាំបាច់សំរាប់មាតាបិតា អាចស្វែងរកឃើញបាននៅតាម គោលការណ៍ណែនាំប្រចាំឆ្នាំសំរាប់មាតាបិតា និងសិស្ស ដែលមានតាំងបង្ហាញនៅតាម **lbschools.net/guidelines** ។

យើងខ្ញុំក៏សូមផ្តល់ជាមធ្យោបាយច្រើនទៀតដែរសំរាប់លោកអ្នកធ្វើការភ្ជាប់ទំនាក់ទំនង និងចូលរួមចំណែកក្នុងកម្មវិធីសិក្សានៃសិស្សរបស់លោកអ្នក ។ ខ្ញុំសូមលើកទឹកចិត្តទៅកាន់លោកអ្នកអោយចូលពិនិត្យយ៉ាងញឹកញាប់អំពីគេហទំព័រនៅតាមសាលារៀននៃសិស្សរបស់លោកអ្នក និងគេហទំព័រ LBUSD របស់យើង ដែលទើបតែបាន ទទួលការរៀបចំសារឡើងវិញ ។ សូមធ្វើការបញ្ជាក់ដោយចូលពិនិត្យអំពី Parent University នៅតាម lbschools.net ហើយលោកអ្នកអាចធ្វើការតាមដានជាមួយយើងខ្ញុំបានក្នុងប្រព័ន្ធ ធ្វីទ័រ អ៊ិនស្តាក្រាម ហ្វេសប៊ុគ និងយូធូប នៅតាម @LongBeachUSD ។ ខ្ញុំក៏សូមអញ្ជើញលោកអ្នកផងដែរអោយធ្វើការតាមដានជាមួយគណនេយ្យ ធ្វីទ័រ ផ្ទាល់ខ្លួនរបស់ខ្ញុំនៅតាម @jbaker000 ។



សូមអរគុណចំពោះជំនួយគាំទ្រពីលោកអ្នក និងសូមជូនពរអោយប្រកបដោយសុវត្ថិភាព និងលទ្ធផលល្អក្នុងឆ្នាំសិក្សា ។



Jill A. Baker, Ed.D.
អគ្គនាយកសាលារៀន

បានចុះផ្សាយនៅខែសីហា 2023

## ទាក់ទងយើងខ្ញុំ

គេហទំព័រមណ្ឌលអប់រំ
**lbschools.net**

គេហទំព័រសាលារៀន
**ឈ្មោះសាលារៀន.lbschools.net**

*ឧទាហរណ៍*
**avalon.lbschools.net**
**los-cerritos.lbschools.net**

**សំរាប់សំនួរផ្សេងៗទៀត សូមទាក់ទង៖**

កម្មវិធីអប់រំសំរាប់កុមារតូចៗ
**lbschools.net/earlylearning**

ការិយាល័យសាលាបឋមសិក្សា/K-8
**(562) 997-8247**

ការិយាល័យអនុវិទ្យាល័យ
**(562) 997-8100**

ការិយាល័យវិទ្យាល័យ
**(562) 997-8115**

## ធ្វើទំនាក់ទំនង

**តាមដាន**
**ជាមួយយើងខ្ញុំ**

**@LongBeachUSD**




អានសំគាល់អំពីព្រឹត្តិការណ៍ប្រចាំខែក្នុងមណ្ឌលអប់រំ ដែលមាននៅតាម **lbschools.net/calendar**

## peachjar សំរាប់ក្រុមគ្រួសារ LBUSD

ក្នុងការប្រឹងប្រែងមួយចំណែកសំរាប់ថែបរិស្ថាន គឺ LBUSD បានធ្វើការកែប្រែអំពីការផ្ញើព័ត៌មានដោយផ្ទេរពីការប្រើក្រដាសទៅជារបៀបប្រើ អ៊ែឡិចត្រូនិច វិញតាមរយៈ Peachjar ។ សេចក្តីប្រកាសផ្សេងៗពី LBUSD ឬស្របតាមការទទួលស្គាល់ពេញច្បាប់ពីអង្គការមិនយកកំរៃ/រដ្ឋាភិបាល គឺនឹងផ្ញើទៅកាន់ អ៊ីមែល របស់លោកអ្នក និងមានតាំងបង្ហាញក្នុង e-flyerboard នៅតាមសាលារៀននៃសិស្សរបស់លោកអ្នក ។

ក្រុមគ្រួសារអាចអានមើលបានអំពីសេចក្តីប្រកាសផ្សេងៗក្នុងពេលបច្ចុប្បន្ន ដែលទាក់ទងកម្មវិធី និងព្រឹត្តិការណ៍ជាបន្តបន្ទាប់ ដោយចុចយកគន្លឹះ Peachjar នៅតាមគេហទំព័រសាលារៀនរៀងៗខ្លួន ។

# បញ្ជីត្រួតពិនិត្យ
## សំរាប់ត្រឡប់ចូលសាលារៀន



- **អានមើលនៅតាម lbschools.net និងគេហទំព័រសាលារៀន** ដើម្បីទទួលព័ត៌មានថ្មីៗ ។

- **ធ្វើការបញ្ជាក់ថា ព័ត៌មានងាយទាក់ទងទៅកាន់លោកអ្នក គឺមានភាពត្រឹមត្រូវមែននៅក្នុង ParentVue ។** គេហទំព័រនេះផ្តល់ឱកាសសំរាប់មាតាបិតាពិនិត្យអំពីព័ត៌មានថ្មីៗ និងអំពីសំណុំរឿងចាស់ៗនៃសិស្សរបស់ពួកគាត់ ដែលមានដូចជា៖ វត្តមានប្រចាំថ្ងៃ លេខពិន្ទុ និងអ្វីផ្សេងបន្ថែម ។ បើសិនជាលោកអ្នកមិនបានទទួល អ៊ីមែល ចិត្ត ឬ ការទាក់ទងតាមទូរស័ព្ទស្ដីអំពីសិស្សរបស់លោកអ្នក ឬ បើសិនជាលោកអ្នកត្រូវការជំនួយរៀបចំបង្កើត គឺសូមទាក់ទងសាលារៀនរបស់លោកអ្នក ។

- **ឆ្លើយបំពេញ អនឡាញ អំពីការបញ្ជាក់ប្រចាំឆ្នាំ ។** ក្រុមគ្រួសារត្រូវបញ្ជាក់ប្រាប់ថា ពួកគេបានទទួល និងបានធ្វើការកែប្រែព័ត៌មានសំខាន់ៗ រួចរាល់ហើយនៅក្នុង ParentVue ។



- **ធ្វើការបញ្ជាក់អំពីម៉ោង ដែលសិស្សរបស់លោកអ្នកចាប់ផ្តើមចូលសាលារៀន ។** ដូចបានជំរាបរួចហើយពីឆ្នាំមុន ដោយសារតែច្បាប់ថ្មី គឺភាគច្រើន វិទ្យាល័យនឹងចាប់ផ្តើមម៉ោងចូលរៀននៅ 8:45 ព្រឹក និង 8 ព្រឹក នៅតាមអនុវិទ្យាល័យក្នុងរដូវស្លឹកឈើជ្រុះនៃឆ្នាំនេះ ។

- **នាំសមាជិកទាំងអស់ក្នុងគ្រួសារ ដែលសមលក្ខណៈអាចទទួលបាន ទៅធ្វើការចាក់ថ្នាំ ។** មន្ត្រីក្រសួងសុខាភិបាលបានសំរេចថា ការចាក់ថ្នាំ គឺមានសុវត្ថិភាព និងប្រសិទ្ធិភាព ។ ការចាក់ថ្នាំ គឺជាចំណែកមួយការពារខ្លួនលោកអ្នក និងអ្នកដទៃ ។ សូមរៀនអានបន្ថែមអំពីក្រសួងសុខាភិបាលប្រចាំក្រុង ឡុងប៊ីច នៅតាមគេហទំព័រ *longbeach.gov/health* ។



- **ប្រយ័ត្នអំពីសកម្មភាពនៃសិស្សរបស់លោកអ្នកនៅតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ។** សូមចងចាំថា សិស្សណាដែលប្រើអំពើគំរាម សូម្បីគ្រាន់តែជាការនិយាយជន្លលេងក៏ដោយ គឺអាចជាប់ការឃុំឃាំង និងទទួលទោសយ៉ាងធ្ងន់បាន រាប់បញ្ចូលផងទាំងការបណ្ដេញចោលពីសាលារៀន ។ បើសិនជាលោកអ្នក ឬ កូនរបស់លោកអ្នកសំគាល់ឃើញ ឬ ស្ដាប់ដឹងអំពីហេតុការអ្វីគួរអោយសង្ស័យ គឺសូមមេត្តានិយាយបង្ហាញ ។

- **ហាត់ប្រើតាមទម្លាប់ថ្មី ។** ទម្លាប់ប្រចាំថ្ងៃ ដូចជា៖ ការភ្ញាក់ និងការស្លៀកពាក់ទាន់ពេល ការទទួលអាហារស្របពេល និងការរៀននៅស៊ាំក្បែរមនុស្សធំ និងក្មេងដទៃ គឺជាចំណែកសំខាន់ទាំងអស់សំរាប់ការផ្លាស់ត្រឡប់ចូលសាលារៀនវិញ ។

# ការប្តេជ្ញាចិត្តរបស់យើងទៅកាន់សុវត្ថិភាព

## សុវត្ថិភាព និង ភាពសន្តិសុខនៅតាមសាលារៀន



សាលារៀនរបស់យើងធ្វើកិច្ចការស្និទ្ធស្នាលជាមួយក្រសួងអនុវត្តច្បាប់រាល់ថ្ងៃ ហើយជារឿយៗ គឺធ្វើនៅក្រោមការមិនបញ្ចេញមុខ ដើម្បីរក្សាសុវត្ថិភាពទៅកាន់សិស្ស ។ យើងធ្វើការកែប្រែជាបន្តអំពីគំរោងសុវត្ថិភាពរបស់យើង ដោយប្រើតាមគោលការណ៍ណែនាំពីក្រសួងអនុវត្តច្បាប់ប្រចាំតំបន់ និងក្រសួងអនុវត្តច្បាប់ជាតិ រួមទាំងជាមួយអ្នកជំនាញការជាតិផ្សេងៗទៀតផង ។ សូមរៀនអានបន្ថែមនៅតាម **lbschools.net/safety** ។

## សេចក្តីរំលឹកអំពីចរាចរ និង មនុស្សដើរ

ចំនួនមនុស្សដើរ និងចរាចរយានយន្តនៅជុំវិញសាលារៀននឹងកើន នៅពេលសាលារៀនចាប់ផ្តើមបើកឡើងវិញ ។ សូមចំណាំទុកអំពី៖




- ការប្រយ័ត្នប្រយែងជាបន្ថែម
- ឈប់ ដើម្បីទុកឱកាសអោយអ្នកដើរឆ្លងទៅមុន
- ជៀសវាងការបើកបរ នៅពេលមានអារម្មណ៍មិនស្រួល
- ឃ្លាំមើល និងគោរពតាមបញ្ជាពីបុគ្គលិកចម្លងផ្លូវ
- ធ្វើតាមក្បួនខ្នាតនៅពេលនាំសិស្សទៅទម្លាក់ចុះ
- បង្ហាត់សិស្សរបស់លោកអ្នកអោយតែងតែដើរឆ្លងនៅតាមកាច់ជ្រុងផ្លូវត្រឹមត្រូវ

## សុខភាព/សុខុមាលភាពនៅតាមផ្ទះ

មាតាបិតាត្រូវបានរំលឹកថា អោយជួយឃ្លាំមើលរាល់ថ្ងៃអំពីរោគសញ្ញាទាំងអស់នេះ ដែលអាចកើតឡើង មុននឹងបញ្ជូនសិស្សទៅរៀន៖



- គ្រុនកំដៅ 100.4 អង្សា ឬ លើស
- ក្អក ឈឺបំពង់ក តឹងច្រមុះ ឬ ហៀរសំបោរ
- ស្ទះដង្ហើម ឬ ពិបាកដកដង្ហើម
- បាត់បង់ជាតិក្លិន ឬ ការធុំក្លិន
- ត្រជាក់ខ្លួន ឬ ឈឺសាច់ដុំ ឬ ដងខ្លួន
- ចង្អោរ ក្អួត ឬ ចុះរាគ

សំរាកនៅផ្ទះ បើសិនជាមានជំងឺ និងទាក់ទងប្រាប់សាលារៀននៃសិស្សរបស់លោកអ្នក ។

នៅថ្ងៃទី7 ខែមិថុនា 2023 គណៈកម្មាធិការអប់រំប្រចាំ LBUSD បានធ្វើការអនុម័តមកលើ ទស្សនៈវិស័យ 2035 ដែលជាទស្សនៈវិស័យទូទាំងសហគមន៍សំរាប់បង្ហាញអំពីមធ្យោបាយ ដែលមណ្ឌលអប់រំគួរបំរើកិច្ចការជួយសិស្សក្នុង ឡុងប៊ីច ចាប់ពីពេលមានកំណើតរហូតដល់កំរិតថ្នាក់ទី12 និងលើសទៅទៀត អោយបានទាន់ឆ្នាំ2035 ។ វាត្រូវបានរៀបចំឡើងជារូបភាព ឬ គោលដៅរបស់មណ្ឌលអប់រំ ដែលរចនារួមគ្នាដោយសិស្ស ក្រុមគ្រួសារ បុគ្គលិក និងសមាជិកសហគមន៍ ហើយនឹងជួយដឹកនាំទៅកាន់ទិសដៅ ឬ គំរោងយុទ្ធសាស្ត្រសំរាប់ LBUSD ។

VISION 2035
Let's reimagine education in LBUSD.

អស់ពេលមួយឆ្នាំមកហើយ គឺសិស្ស ក្រុមគ្រួសារ សមាជិកសហគមន៍ និងសម្ព័ន្ធដឹកនាំទស្សនៈវិស័យ 2035 ប្រចាំ LBUSD ដែលជាក្រុមជំរើសមានគ្នា 103 នាក់ជាសិស្ស បុគ្គលិក ក្រុមគ្រួសារ និងសមាជិកសហគមន៍ បានចូលរួមក្នុងកិច្ចប្រជុំ និងឆ្លើយតបតាមការស្ទង់វាស់មតិសំរាប់ជួយបង្កើតទស្សនៈវិស័យ 2035 ។

លទ្ធផលទីបញ្ចប់មានជា បួន ចំណែក៖ រូបភាពអ្នករៀនចប់ រូបភាពមនុស្សធំ រូបភាពប្រព័ន្ធ និងសេចក្តីបញ្ជាក់អំពីឧត្តមភាពនៃតំលៃស្នូល ។ ពិពណ៌នាយ៉ាងពេញលេញអំពីរូបភាពទាំងអស់នេះ និងគំរោងទស្សនៈវិស័យ 2035 ស្របតាមការបានទទួលអនុម័តរួចមក គឺមានតាំងបង្ហាញនៅតាម **lbschools.net/strategicplan** ។

សូមរង់ចាំទទួលព័ត៌មានបន្ថែមអំពី ទស្សនៈវិស័យ 2035 ក្នុងឆ្នាំសិក្សា 2023-24 ។